**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)**

Committee For Free And Fair Elections In Cambodia (COMFREL)

ទីស្នាក់ការកណ្ដាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.

P.O. Box 1145, Tel: (855) 23 884 150/12 942 019, Fax: (855) 23 883 750 E-mail: comfrel@online.com.kh, comfrel@comfrel.org or comfreladmin@online.com.kh, Site : www.comfrel.org

**ខុមហ្វ្រែល COMFREL**



**គណៈកម្មាធិការនាយក**
BOARD OF DIRECTORS

លោក **ធុន សារាយ**
**Mr. THUN SARAY**
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន **ADHOC**

លោក **សុក សំអឿន**
**Mr. SOK Sam Oeun**
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក **CDP**

លោក **យឹម ប៉ូ**
**Mr. YIM Po** អគ្គលេខាធិការ
និង នាយក **CCPCR**

អ្នកស្រី **ស៊ុន ចាន់សែន**
**Mrs. SUN Chansen**
ប្រធាន **KYA**

លោក **មុំ សារិន**
**Mr. MOM Sarin**
នាយក **HRCDO**

លោកស្រី **ពឹង យក់ហៀប**
**Mr. PEUNG Yok Hiep**
នាយិកា **LAC**

លោកស្រី **ទីវ សារ៉ាយេត**
**Ms. TIV Sarayet**
សហនាយិកា **WMC**

កញ្ញា **សយ សារ៉ា វឌ្ឍនី**
**Miss. SAY Sara Vathany**
នាយិកា **CWCC**

លោក **គីម សុវណ្ណ**
**Mr. KIM Sovann**
នាយក **VIGILANCE**

លោក **អាង ច័ន្ទឫទ្ធិ**
**Mr. ANG Chanrith**
នាយក **KKKHRO**

លោក **យង់ គិមអេង**
**Mr. YONG Kim Eng**
នាយក **PDP-Center**

លោក **ភួង សិទ្ធិ**
**Mr. PHUONG Sith**

លោក **សឺន សែត**
**Mr. SEN Set**


ស.ប្រ.ក.ព/លេខ ០១/១០ គ.ប.ស.យ/អ.ក

# សេចក្ដីប្រកាសព័ត៌មាន
# ស្ដីពី
# លទ្ធផលស្រាវជ្រាវ "ការចូលរួម និងអភិបាលកិច្ចប្រជាធិបតេយ្យ"

*ភ្នំពេញ, ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១០*

គណៈកម្មាធិការខុមហ្វ្រែល នៅថ្ងៃនេះបានរៀបចំសិក្ខាសាលាដើម្បីផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ និងពិភាក្សាទៅលើគោលការណ៍ស្ដីពី "ការចូលរួម និងអភិបាលកិច្ចប្រជាធិបតេយ្យ" និងផ្សព្វផ្សាយលទ្ធផលនៃលក្ខខណ្ឌសន្ទស្សន៍[១] នៃវិស័យអាទិភាពនៅ ២៤ ខេត្ត-រាជធានី ដែលកំណត់ដោយម្ចាស់ឆ្នោត និងរកវិធីសាស្ត្រដែលម្ចាស់ឆ្នោតត្រូវធ្វើបន្តដើម្បីឱ្យលក្ខខណ្ឌសន្ទស្សន៍ទាំងនេះត្រូវបានអនុវត្ត។

លទ្ធផលនៃការស្រាវជ្រាវនៅឆ្នាំ ២០០៩ ស្ដីពី "ការចូលរួម និងអភិបាលកិច្ចប្រជាធិបតេយ្យ" ទៅលើអ្នកមានសិទ្ធិបោះឆ្នោត[២] ចំនួន **៨.៦៧៨ នាក់ ទូទាំងប្រទេស** រកឃើញថា ការយល់ដឹង ឬការស្គាល់របស់ប្រជាពលរដ្ឋចំពោះតំណាងរាស្ត្រនៅមានកម្រិតនៅឡើយ។ ប្រហែលតែ ៣៨% (ប្រមាណ ៣ លាននាក់) ប៉ុណ្ណោះនៃអ្នកមានសិទ្ធិបោះឆ្នោតដែលស្គាល់អ្នកតំណាងរាស្ត្រ (ប្រហែល ២៨% ស្គាល់ទាំងឈ្មោះអ្នកតំណាង-រាស្ត្រ និងប្រហែល ១០% មិនស្គាល់ឈ្មោះ)។

ភាគរយនេះកាន់តែតិចសម្រាប់អ្នកដែលបានទំនាក់ទំនងជាមួយអ្នកតំណាងរាស្ត្រ ដោយមានតែ ៣.៥% នៃអ្នកមានសិទ្ធិបោះឆ្នោតប៉ុណ្ណោះដែលធ្លាប់បានធ្វើការទំនាក់ទំនងជាមួយអ្នកតំណាងរបស់ខ្លួន។ ភាគច្រើនលើសលប់ ៧៥% នៃអ្នកបានទំនាក់ទំនងជាមួយតំណាងរាស្ត្របានទាក់ទងតំណាងរាស្ត្រដើម្បីសុំអន្តរាគមន៍រឿងវិវាទផ្សេងៗដែលខ្លួន ឬសហគមន៍ខ្លួនបានជួបប្រទះ។

លទ្ធផលក៏បានបង្ហាញដែរថា ក្នុងចំណោមអ្នកមានសិទ្ធិបោះឆ្នោតដែលបានទំនាក់ទំនងអ្នកតំណាងរាស្ត្រមាន ៨៤% គឺពេញចិត្តទៅនឹងសកម្មភាពរបស់អ្នកតំណាងរាស្ត្រ។

---

[១] ការសន្យាណាដែលមានសូចនាករច្បាស់លាស់ អាចមានជាក់ស្ដែង អាចវាស់បានដូចជាការអនុម័តច្បាប់ ការបង្កើតស្ថាប័ន ឬជាសកម្មភាព ការអនុវត្តអ្វីមួយច្បាសលាស់ ដោយមានគោលដៅ ពេលវេលា ឬមានចំនួនកំណត់ច្បាស់លាស់ ឬមួយប្រៀបធៀបទៅនឹងអត្រាណាមួយច្បាស់លាស់។

[២] អ្នកមានសិទ្ធិបោះឆ្នោត គឺសំដៅទៅលើប្រជាពលរដ្ឋដែលមានអាយុ ១៨ ឆ្នាំឡើងទៅ ហើយដែលសិទ្ធិបោះឆ្នោតរបស់គាត់មិនត្រូវបានដកហូត

ចំណែកការចូលរួមរបស់កងកំលាំងប្រដាប់អាវុធក្នុងសកម្មភាពនយោបាយ មានអ្នកសិទ្ធិបោះឆ្នោតប្រមាណ ៤២% មិនគាំទ្រ ខណៈដែលអ្នកគាំទ្រមានតែប្រហែល ២៧% និងប្រមាណ ៣១% មិនមានយោបល់។

អ្នកមានសិទ្ធបោះឆ្នោត ៧១.៥៧% បានគាំទ្រទៅនឹងការបង្កើតច្បាប់ ឬគោលនយោបាយដើម្បីបំរុងអាសនៈសំរាប់ស្ត្រី។

ទាក់ទងនឹងកិច្ចការមូលដ្ឋាន អ្នកមានសិទ្ធិបោះឆ្នោតប្រមាណ ៣១% បានយល់ពីការចូលរួមសកម្មភាពនៅក្នុងឃុំ/សង្កាត់។ ជាមួយគ្នានេះ ប្រជាពលរដ្ឋប្រមាណ ៦៤.២៩% មានការពេញចិត្តទៅលើសមិទ្ធិផលរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់។

លោក **សុក សំអឿន** អនុប្រធានគណៈកម្មាធិការនាយកខុមហ្វ្រែល និងជាប្រធានអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជាបានឱ្យដឹងថា *"តំណាងរាស្ត្រ និងរាជរដ្ឋាភិបាលគួរតែខិតខំចំពោះការចូលរួមរបស់ប្រជាពលរដ្ឋ និងពង្រឹងការទំនាក់ទំនង និងគណនេយ្យភាពរបស់ខ្លួនចំពោះម្ចាស់ឆ្នោត"*។ លោក **សុក សំអឿន** បានផ្តល់យោបល់ថា សភា រាជរដ្ឋាភិបាល និងគណបក្សនយោបាយគួរពិចារណាមតិភាគច្រើនរបស់ប្រជាពលរដ្ឋដែលថា កងកំលាំងប្រដាប់អាវុធមិនត្រូវចូលរួមក្នុងសកម្មភាពនយោបាយ។

ការស្រាវជ្រាវនេះមានកិច្ចសហការជាមួយគណៈកម្មាធិការនិកហ្វិច មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព និងសមាគមយុវជនខ្មែរធ្វើឡើងកាលពីខែ កុម្ភៈ ដល់ខែមិថុនា ឆ្នាំ ២០០៩ ក្រោមការគាំទ្រថវិកាពីម្ចាស់ជំនួយដូចជា កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP), ស្ថានទូតអង់គ្លេស, Forum Syd និង NPA ។

នៅក្នុងសិក្ខាសាលានេះដែរ ក៏បានបង្ហាញពីលទ្ធផលនៃលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនៅ ២៤ ខេត្ត-រាជធានីផងដែរ។ លក្ខខណ្ឌសន្ទស្សន៍ទាំងនេះ គឺត្រូវបានកំណត់ដោយម្ចាស់ឆ្នោតក្នុងមណ្ឌល (ខេត្ត-រាជធានី) នីមួយៗ។

លោក **ធន សារាយ** ប្រធានគណៈកម្មាធិការនាយកខុមហ្វ្រែល និងជាប្រធានសមាគមការពារសិទ្ធិមនុស្ស អាដហុក បានលើកឡើងថា *"សេចក្តីត្រូវការដែលម្ចាស់ឆ្នោតខ្លួនឯងជាអ្នកទាមទារដោយផ្ទាល់ ក៏ជាព័ត៌មានយ៉ាងសំខាន់សម្រាប់មន្ត្រីជាប់ឆ្នោតក្នុងការដោះស្រាយជួយប្រជាពលរដ្ឋនៅ និងអនុវត្តលក្ខខណ្ឌសន្ទស្សន៍ក្នុងមណ្ឌលរបស់ខ្លួន។ ប្រជាពលរដ្ឋជាប់ឆ្នោតត្រូវធ្វើការវាយតម្លៃពីប្រសិទ្ធិភាពនៃការអនុវត្ត និងការសម្រេចបានរបស់មន្ត្រីជាប់ឆ្នោតចំពោះការសន្យា។*

នៅក្នុងសិក្ខាសាលានេះ យុទ្ធសាស្ត្រផ្សេងៗនឹងត្រូវបានពិភាក្សាដើម្បីជម្រុញឱ្យលក្ខខណ្ឌសន្ទស្សន៍ទាំងនេះត្រូវបានអនុវត្ត ហើយគណៈកម្មាធិការខុមហ្វ្រែលនឹងរៀបចំវេទិកានៅតាមបណ្តាខេត្តមួយចំនួនដើម្បីឱ្យម្ចាស់ឆ្នោតធ្វើការវាយតម្លៃដោយផ្តល់ជាពិន្ទុទៅលើប្រសិទ្ធិភាពការងាររបស់មន្ត្រីជាប់ឆ្នោតទៅលើលក្ខខណ្ឌសន្ទស្សន៍ទាំងនេះ។

ខុមហ្វ្រែល ក៏បានបញ្ជូនរបាយការណ៍ស្តីពីលទ្ធផលនៃលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទៅកាន់រាជរដ្ឋាភិបាល និងសមាជិកសភាទាំងអស់។

សម្រាប់របាយការណ៍លទ្ធផលលម្អិតនៃការស្រាវជ្រាវនេះ និងលទ្ធផលនៃលក្ខខណ្ឌសន្ទស្សន៍ សូមចូលទៅកាន់គេហទំព័រខុមហ្វ្រែលៈ www.comfrel.org

*សម្រាប់ព័ត៌មានផ្សេងៗសូមទាក់ទងៈ*

- លោក **គល់ បញ្ញា** នាយកប្រតិបត្តិ ខុមហ្វ្រែល ទូរស័ព្ទៈ **០១២ ៩៤២ ០១៧**
- លោក **សុខ ពិន្ទុរឿ** អ្នកសម្របសម្រួលផ្នែកអង្កេត ខុមហ្វ្រែល ទូរស័ព្ទៈ **០៨៩ ៥២៥ ៤៤៦**